# ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា

## ការិយាល័យ ចុះឈ្មោះ និង ចាត់តាំងសិស្ស

## វិធីជ្រើសរើសសាលា

## សំណួរដែលគេឧស្សាសួរ សម្រាប់មាតាបិតារបស់សិស្សវិទ្យាល័យ

**តើអ្នកណាគួរចូលរួមក្នុងវិធីជ្រើសរើសសាលានេះ?**

វិធីជ្រើសរើសសាលាគឺសម្រាប់សិស្សានុសិស្ស និង ក្រុមគ្រួសារ ទាំងអស់ ដែលចង់ដាក់ពាក្យសុំចូលរៀននៅសាលាដែល<u>**នៅក្រៅ**</u>ព្រំដែននៃតំបន់រស់នៅរបស់ពួកគេ សម្រាប់ថ្នាក់មត្តេយ្យ ដល់ ថ្នាក់ទី១២ ដែលចូលរៀននៅ ខែកញ្ញា។

**តើការជ្រើសរើសរបស់សិស្សមានអ្វីខ្លះ?**

ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា មានការជ្រើសរើសជាច្រើនសម្រាប់សិស្សានុសិស្ស។ ជាទូទៅ ក្រសួងមានសាលាបីប្រភេទ ដូចរៀបរាប់ខាងក្រោមនេះ។

**សាលានៅក្នុងតំបន់** → សាលាទាំងនេះទទួលសិស្សដែលរស់នៅក្នុងព្រំដែលរបស់សាលា។ ក្រសួងមានការចាប់ឆ្នោតបំពេញកន្លែងដែលនៅទំនេរ សម្រាប់សិស្សានុសិស្សដែលរស់នៅក្រៅព្រំដែនសាលា។

**សាលាដែលទទួលសិស្សទូទាំងក្រុង** → សាលាទាំងនេះមានលក្ខណវិនិច្ឆ័យសម្រាប់ការទទួលសិស្ស ហើយសិស្សទូទាំងក្រុងអាចដាក់ពាក្យសុំចូលរៀននៅ សាលាទាំងនេះ។ ក្រុមនៅតាមសាលាវាយតម្លៃបេក្ខជនទាំងអស់ រួចហើយសម្រេចចិត្តថាតើគួរដាក់បេក្ខជននៅក្នុងការចាប់ឆ្នោតដោយគ្រឿងអេឡិចត្រូនិច ដែលជ្រើសរើសសិស្សានុសិស្សឲ្យចូលរៀន។

**សាលាទទួលសិស្សដែលមានលក្ខណៈ** → សាលាទាំងនេះជា «សាលាដែលទាក់ទាញសិស្ស» ហើយសាលានីមួយៗមានលក្ខណៈវិនិច្ឆ័យសម្រាប់ការទទួលសិស្ស រៀងៗខ្លួន។ លក្ខណៈវិនិច្ឆ័យទាំងនោះមាន របាយការណ៍ពិន្ទុ វត្តមានអវត្តមាន ទៀងទាត់ពេល អាកប្បកិរិយា និង ពិន្ទុនៃការប្រឡងទូទៅ។ ក្រុមនៅតាមសាលា វាយតម្លៃបេក្ខជនទាំងអស់ រួចហើយធ្វើការសម្រេចចិត្តក្នុងការទទួលសិស្ស។

**កូនរបស់ខ្ញុំដាក់ពាក្យសុំចូលរៀននៅ វិទ្យាល័យទទួលសិស្សដែលមានលក្ខណៈសម្បត្តិពិសេស តើខ្ញុំត្រូវធ្វើអ្វីខ្លះ?**

- សម្រាប់សិស្សរបស់ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ាបច្ចុប្បន្ន
  - ដាក់ពាក្យសុំទៅរៀនសាលាណាដែលអ្នកចាប់អារម្មណ៍ ដោយបំពេញលិខិតជ្រើសរើសសាលាតាមអ៊ិនធ័រណិត។
  - គេនឹងផ្ញើ សំណុំឯកសារសិក្សារបស់កូនលោកអ្នកទៅសាលាដោយស្វ័យប្រវត្ត តាមរយៈនៃប្រព័ន្ធជ្រើសរើសសាលារបស់ក្រសួងអប់រំ។
  - សាលាខ្លះតម្រូវឲ្យមាន ការសរសេរអត្ថបទ ការធ្វើសម្ភាសន៍ ឬ ការសម្តែងសាកល្បង។ សូមមើលវិបសៃរបស់សាលា ដើម្បីពិនិត្យមើលការតម្រូវសម្រាប់ការទទួលសិស្សឲ្យចូលរៀនរបស់សាលានីមួយ។
  - សូមទាក់ទងសាលា បើសិនត្រូវការ ការធ្វើសម្ភាសន៍ ឬ ការសម្តែងសាកល្បង។

- សម្រាប់សិស្សដែលមិនមែនជាសិស្សរបស់ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ាបច្ចុប្បន្ន
  - ដាក់ពាក្យសុំទៅរៀនសាលាណាដែលអ្នកចាប់អារម្មណ៍ ដោយបំពេញលិខិតជ្រើសរើសសាលាតាមអ៊ិនធ័រណិត។
  - វិទ្យាល័យទទួលសិស្សដែលមានលក្ខណៈសម្បត្តិពិសេស និង ដែលទទួលសិស្សទូទាំងក្រុង ត្រូវការសំណុំឯកសារនៃ ការសិក្សា វត្តមានអវត្តមាន និង អាកប្បកិរិយា សម្រាប់ការទទួលសិស្សឲ្យចូលរៀន ដោយមូលហេតុនេះហើយ គេត្រូវការច្បាប់ចម្លងនៃសំណុំឯកសារថ្មីៗរបស់កូនលោកអ្នក។
  - លោកអ្នកត្រូវតែយកព័ត៌មានខាងក្រោមនេះទៅសាលានីមួយៗ ដែលមានឈ្មោះនៅក្នុងលិខិតដាក់ពាក្យសុំចូលរៀនរបស់កូនលោកអ្នក ដោយផ្ទាល់
    - ទិនន្នន័យនៃព្រឹត្តិប័តពិន្ទុសិស្សរបស់ក្រសួងអប់រំ និង
    - ច្បាប់ចម្លងនៃការប្រឡងទូទៅថ្មីៗរបស់កូនលោកអ្នក
    - តារាងខាងក្រោមនេះជួយឲ្យលោកអ្នកដឹងថាត្រូវផ្តល់ឯកសារអ្វីខ្លះ។

| | |
|---|---|
| ដាក់ពាក្យសុំចូលរៀនថ្នាក់ទី៩ | ផ្តល់ព័ត៌មានអំពីពិន្ទុនៃ ការសិក្សា និង ការប្រឡងទូទៅ សម្រាប់ថ្នាក់ទី៧ |
| ដាក់ពាក្យសុំចូលរៀនថ្នាក់ទី១០ | ផ្តល់ព័ត៌មានអំពីពិន្ទុនៃ ការសិក្សា និង ការប្រឡងទូទៅ សម្រាប់ថ្នាក់ទី៨ |
| ដាក់ពាក្យសុំចូលរៀនថ្នាក់ទី១១ | ផ្តល់ព័ត៌មានអំពីពិន្ទុនៃ ការសិក្សា និង ការប្រឡងទូទៅ សម្រាប់ថ្នាក់ទី៩ |
| ដាក់ពាក្យសុំចូលរៀនថ្នាក់ទី១២ | ផ្តល់ព័ត៌មានអំពីពិន្ទុនៃ ការសិក្សា និង ការប្រឡងទូទៅ សម្រាប់ថ្នាក់ទី១០ |

**តើខ្ញុំត្រូវធ្វើដូចម្តេចដើម្បីឲ្យដឹងពីតម្រូវការនៃការទទួលសិស្សឲ្យចូលរៀន របស់សាលា?**

បញ្ជីរាយឈ្មោះវិទ្យាល័យនៅក្នុងអ៊ិនធ័រណិតរបស់ក្រសួងមានតម្រូវការនៃការទទួលសិស្សឲ្យចូលរៀនរបស់វិទ្យាល័យនីមួយៗ។ អ្នកផ្តល់ឱវាទ ឬ គ្រូ របស់លោកអ្នកក៏អាចជួយពន្យល់ពីតម្រូវការនៃការទទួលសិស្សឲ្យចូលរៀនរបស់សាលានីមួយៗ។

**កូនរបស់ខ្ញុំដាក់ពាក្យសុំចូលរៀននៅវិទ្យាល័យក្នុងតំបន់ៗ តើខ្ញុំត្រូវធ្វើអ្វីខ្លះ?**

ពិនិត្យមើល ការសិក្សា ឯកទេស និង កម្មវិធីអប់រំផ្នែក អាជីព និង បច្ចេកវិទ្យា ដែលគេផ្តល់ឲ្យនៅវិទ្យាល័យរបស់ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យា។ ដាក់ពាក្យសុំទៅរៀននៅសាលាណាដែលអ្នកចាប់អារម្មណ៍ ដោយបំពេញលិខិតជ្រើសរើសសាលាតាមអ៊ិនធ័រណិត។

**តើពេលកំណត់សម្រាប់វិធីជ្រើសរើសសាលា នៅពេលណា?**

*(ថ្ងៃខែ អាចមានការផ្លាស់ប្តូរ)*

| **ខែ** | **សកម្មភាព** |
|---|---|
| តុលា | ប្រគល់លិខិតដាក់ពាក្យសុំចូលរៀន |
| មករា ដល់ កុម្ភៈ | ការវាយតម្លៃលិខិតដាក់ពាក្យសុំចូលរៀននៅតាមសាលា (សាលាដែលទទួលសិស្សតាមលក្ខណៈវិនិច្ឆ័យ) |
| ចុង ខែកុម្ភៈ | ធ្វើការចាប់ឆ្នោត |
| ខែមិនា | ផ្ញើលិខិតជូនដំណឹងដំបូងអំពីស្ថានការណ៍ |
| ចុងខែមិនា | ជ្រើសរើសយកឈ្មោះសិស្សចេញពីបញ្ជីរង់ចាំ |
| ចុង ខែមេសា | ផ្ញើលិខិតជូនដំណឹងចុងក្រោយអំពីស្ថានការណ៍ |

**តើក្រសួងនឹងទាក់ទងផ្តល់ដំណឹងថ្មីៗមកខ្ញុំដោយវិធីណា?**

- សម្រាប់សិស្សរបស់ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យាបច្ចុប្បន្ន - គេនឹងផ្ញើលិខិតជូនដំណឹងទាំងអស់ទៅសិស្ស និង ក្រុមគ្រួសារ តាមរយៈទំព័រវ៉ិបសៃសម្រាប់សិស្ស និង មាតាបិតា។ នេះរួមទាំង សេចក្តីសម្រេចលើការជ្រើសរើសសាលាទាំងអស់។

- សម្រាប់សិស្សដែលមិនមែនជាសិស្សរបស់ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យាបច្ចុប្បន្ន - គេនឹងផ្ញើលិខិតជូនដំណឹងទាំងអស់ទៅ តាមរយៈអ៊ីមែលដែលបានផ្តល់ឲ្យ នៅពេលដាក់លិខិតសុំចូលរៀន។ នេះរួមទាំង សេចក្តីសម្រេចលើការជ្រើសរើសសាលាទាំងអស់។

**តើខ្ញុំគួរទៅមើលសាលា ឬទេ?**

គួរទៅមើល។ ក្រសួងអប់រំកំពុងប្រមូលរៀបចំបញ្ជីថ្ងៃខែនៃកម្មវិធីដើរមើលវិទ្យាល័យ។ កាលវិភាគនឹងមាននៅក្នុងវ៉ិបសៃ schoolselect.philasd.org នៅពេលគេរៀបចំថ្ងៃខែរួចរាល់។ សូមទាក់ទងទៅសាលាដែលលោកអ្នកមានចំណាប់អារម្មណ៍ ដើម្បីសួរពី ថ្ងៃខែ និង ម៉ោង សម្រាប់ពេលដើរមើលសាលា ឬ ឱកាសផ្សេងទៀតដើម្បីទៅមើលសាលា របស់ពួកគេ។

**បើសិនជាខ្ញុំគ្មានលក្ខណៈសម្បត្តិគ្រប់គ្រាន់តាមលក្ខណៈវិនិច្ឆ័យនៃការជ្រើសរើសរបស់សាលា តើខ្ញុំគួរតែដាក់ពាក្យសុំចូលរៀន ឬទេ?**

គួរតែដាក់ យើងជំរុញឲ្យសិស្សដែលមានចំណាប់អារម្មណ៍ទាំងអស់ដាក់ពាក្យសុំចូលរៀន ប៉ុន្តែសម្រាប់តែអ្នកដែលមានលក្ខណៈសម្បត្តិជិតគ្រប់គ្រាន់តាមការតម្រូវ។ បើមានលក្ខណៈសម្បត្តិជិតគ្រប់គ្រាន់តាមការតម្រូវ នាយកសាលានៅសាលាដែលជ្រើសរើសសិស្ស នឹងស្នើសុំលិខិតគាំទ្រពីមនុស្សពេញវ័យដែលស្គាល់សិស្ស ពីសាលារបស់បេក្ខជនដាក់ពាក្យ។ ការធ្វើសម្ភាសន៍ក៏អាចជួយបានច្រើនដែរ។

**បើសិនជាគេមិនទទួលខ្ញុំឲ្យចូលរៀននៅសាលាដែលខ្ញុំបានជ្រើសរើសទេ តើខ្ញុំត្រូវធ្វើដូចម្តេច?**

សូមចាំថា អ្នកអាចមានឱកាសឲ្យគេជ្រើសរើសច្រើនជាង បើសិនជាអ្នកដាក់ពាក្យសុំចូលរៀននៅសាលាដែលត្រូវនឹង សំណុំឯកសារនៃការសិក្សារបស់អ្នក និង មុខជំនាញដែលអ្នកមានចំណាប់អារម្មណ៍។ សូមកត់សម្គាល់ថា គេធានាទទួលសិស្សានុសិស្សឲ្យចូលរៀននៅវិទ្យាល័យដែលនៅក្នុងតំបន់របស់ខ្លួន។

**តើសិស្សដែលមាន IEPs ឬ សិស្សដែលត្រូវការរៀនភាសាអង់គ្លេស អាចដាក់ពាក្យសុំចូលរៀននៅវិទ្យាល័យដែលមានការជ្រើសរើសសិស្ស បានដែរឬទេ?**

គេជំរុញឲ្យសិស្សានុសិស្សទាំងអស់ដាក់ពាក្យសុំចូលរៀននៅវិទ្យាល័យណាដែលពួកគេចាប់អារម្មណ៍ បើសិនជាពួកគេមានលក្ខណៈសម្បត្តិត្រូវតាមមូលដ្ឋាននៃការតម្រូវ។ ក្រសួងសម្រួលវិធីគាំទ្រសម្រាប់សិស្សានុសិស្សថ្នាក់ទី៨ ដែលដាក់ពាក្យសុំចូលរៀននៅវិទ្យាល័យដែលមានការជ្រើសរើសសិស្ស ហៅថា វិធីគាំទ្ររបស់លីហ្គា (LeGare)។ សិស្សានុសិស្សដែលមាន កម្មវិធីអប់រំផ្ទាល់ខ្លួន (IEPs) ឬ សិស្ស ELLs អាចស្វែងយល់បន្ថែមទៀតពី អ្នកផ្តល់ឱវាទ ឬ នាយកសាលា និងពី ការិយាល័យផ្តល់ជំនួយពិសេស លេខ ២១៥-៤០០-៤១៧០។

**តើខ្ញុំអាចរកជំនួយសម្រាប់ការជ្រើសរើសវិទ្យាល័យ នៅទីណាទៀត?**

គេជំរុញឲ្យ សិស្សានុសិស្ស និង ក្រុមគ្រួសារ សហការយ៉ាងជិតស្និតជាមួយ អ្នកផ្តល់ឱវាទនៅសាលារបស់ពួកគេ។ ការណែនាំដែលទាក់ទងនឹង ការជ្រើសរើសសាលា និង វិធីសាស្ត្រ ក៏មាននៅតាម មជ្ឈមណ្ឌលព័ត៌មានសម្រាប់មាតាបិតា និងក្រុមគ្រួសារ ផងដែរ។ មាតាបិតាក៏អាចប្រើវ៉ិបសៃរបស់ក្រសួង ដែលគាត់អាចមើល ព័ត៌មានអំពីសាលា ការដាក់ពាក្យសុំចូលរៀនតាមអ៊ិនធ័រណិត និង អាចប្រើព័ត៌មានផ្សេងៗទៀត ដែលទាក់ទងនឹងវិធីនេះ។